# សេចក្តីព្រាង

# គោលការណ៍ណែនាំ ស្តីអំពី

## ការល្បាតនៅប្រព័ន្ធស្រះជម្រកត្រី
## សហគមន៍

## មាតិកា


១. សេចក្តីផ្តើម ....................................................................2

១.១ កត្តាគម្រាមកំហែងចំពោះស្រះជម្រកត្រី ....................................................................2

១.២ អត្ថប្រយោជន៍នៃគោលការណ៍ណែនាំ ....................................................................2

១.៣ វិធីសាស្ត្រក្នុងការរៀបចំ ....................................................................3

២. គោលបំណងល្បាត សមាសភាព និងតួនាទីក្រុមល្បាត ....................................................................3

២.១ គោលបំណងនៃការល្បាត ....................................................................3

២.២ ការចងក្រងសមាសភាពក្រុមល្បាត ....................................................................4

២.២ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមល្បាត ....................................................................4

៣. ទីតាំង និងពេលវេលា ល្បាត ....................................................................5

៣.១ ផ្នែកស្រះជម្រកត្រី ....................................................................5

៣.២ ផ្នែកផ្លូវត្រីចរាចរ ....................................................................5

៣.៣ ផ្នែកវាលស្រែលិចទឹក ....................................................................5

៤. ជំហានក្នុងការល្បាតស្រះជម្រកត្រី ....................................................................7

ជំហានទី១៖ ការយល់ដឹងពីច្បាប់ជលផល និងលក្ខន្តិករបស់សហគមន៍ ....................................................................7

ជំហានទី២៖ សម្ភារៈល្បាត ....................................................................8

ជំហានទី៣៖ វិធានការអំឡុងពេលល្បាត ....................................................................8

ជំហានទី៤៖ ការត្រួតពិនិត្យ និងវាយតម្លៃ ....................................................................9

ឧបសម្ព័ន្ធ ....................................................................14

ឯកសារយោង ....................................................................Error! Bookmark not defined.

# ១. សេចក្តីផ្តើម

ស្រះជម្រកត្រីសហគមន៍ត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៨ ដល់បច្ចុប្បន្ន មានចំនួនប្រមាណ៩១៥ (ទិន្នន័យជលផលឆ្នាំ២០២១)។ តាមរយៈការស្រាវជ្រាវរបស់អង្គការវលហ្វិស ការគ្រប់គ្រងស្រះជម្រកត្រីបានល្អ បានបង្កើនផលចាប់ត្រីប្រមាណ៧១% ដល់គ្រួសារក្រីក្រដែលពឹងផ្អែកលើការនេសាទត្រីតាមវាលស្រែ។ ការគ្រប់គ្រងស្រះជម្រកត្រីសហគមន៍ គឺរួមបញ្ចូលសកម្មភាពជាច្រើនមានដូចជា ការជីកស្តារស្រះ និងប្រឡាយ ធ្វើផ្លូវត្រីចេញចូល ការដាក់សម្រាស់ ។ល។ ក្នុងនោះ ល្បាតគឺជាសកម្មភាពមួយសំខាន់។

ការល្បាតត្រឹមត្រូវ នាំមកនូវការថែរក្សាត្រីមេពូជនៅក្នុងស្រះជម្រកត្រី[1]នៅរដូវប្រាំង ដើម្បីបន្តការបង្កកំណើត និងពងកូននៅតាមប្រព័ន្ធស្រះជម្រកត្រី នៅរដូវវស្សានាឆ្នាំបន្ទាប់ ដែលរួមចំណែកផ្តល់នូវសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

## ១.១ កត្តាគម្រាមកំហែងចំពោះស្រះជម្រកត្រី

ត្រីនៅតាមប្រព័ន្ធស្រះជម្រកត្រីជាប្រភពអាហារដ៏សំខាន់មួយ និងផ្តល់ប្រាក់ចំណូលដល់ប្រជាជនរាប់លាននាក់នៅជនបទនៃប្រទេសកម្ពុជា។ បច្ចុប្បន្នកំពុងប្រឈមនូវកត្តាជាច្រើន មានដូចជា កំណើនប្រជាពលរដ្ឋ បម្រែបម្រួលអាកាសធាតុ បាត់បង់ទីជម្រក បទល្មើសនេសាទ ។ល។ បញ្ហាប្រឈមនេះ បាននឹងកំពុងគម្រាមកំហែងទាំងបរិមាណ និងគុណភាពត្រីធម្មជាតិក្នុងស្រុក។

នាដើមរដូវវស្សា នៅពេលភ្លៀងធ្លាក់ច្រើន ស្រះជម្រកត្រីតភ្ជាប់ឡើងវិញទៅនឹងវាលស្រែ ត្រីចរាចរណ៍ចេញពីស្រះទៅវាលស្រែ តាមផ្លូវត្រីចេញចូល ឬប្រឡាយ ដើម្បីពងកូន លូតលាស់ និងធំធាត់ នៅតាមវាលស្រែ។ នាចុងរដូវវស្សា ទឹកនៅតាមវាលស្រែចាប់ផ្តើមស្រក ត្រីចាប់ផ្តើមវិលត្រឡប់មកស្រះជម្រកត្រីវិញ។ បទល្មើសនេសាទតែងកើតមានឡើងនៅតាមផ្លូវត្រីចេញចូល មានដូចជា ការដាក់ឧបករណ៍ដើម្បីរាំងស្ទាក់ចាប់ត្រី ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ផ្សេងៗ។ អំឡុងពេលរដូវប្រាំងដែលមានរយៈពេល ៦ខែ ត្រីជ្រកកោនក្នុងស្រះជម្រកត្រី ក្នុងពេលនោះបទល្មើសនេសាទកើតមាន។

## ១.២ អត្ថប្រយោជន៍នៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំស្តីអំពី ការល្បាតស្រះជម្រកត្រីសហគមន៍ បានផ្តួចផ្តើមរៀបចំដើម្បី៖

- ជាជំនួយបច្ចេកទេស និងចំណេះដឹងដល់ក្រុមល្បាតរបស់សហគមន៍ស្រះជម្រកត្រី ដើម្បីការពារពូជត្រី ទប់ស្កាត់សកម្មភាពនេសាទខុសច្បាប់

[1] ជាកន្លែងត្រីជ្រកកោនក្នុងរដូវប្រាំង នៅពេលផ្លូវទឹកនិងវាលស្រែត្រូវបានកាត់ផ្តាច់ដោយការរីងរាក់។

- ឆ្លើយតបទៅនឹងតម្រូវការសកម្មភាពល្បាត ដែលធ្វើជារឿយៗដោយគណៈកម្មការសហគមន៍ស្រះជម្រកត្រី អាជ្ញាធរដែនដី និងខណ្ឌរដ្ឋបាលជលផល ស្របពេលដែលគោលការណ៍ណែនាំមិនទាន់បានរៀបចំឡើង
- ជាប្រភពឯកសារយោង និងផ្លូវមួយសម្រាប់ជួយអោយសហគមន៍ស្រះជម្រកត្រីទូទាំងប្រទេសកម្ពុជា ស្ថាប័ន អង្គការដៃគូ យកទៅប្រើប្រាស់ និងអនុវត្តសកម្មភាពល្បាតប្រកប ដោយប្រសិទ្ធភាព
- រួមចំណែកក្នុងការផ្តល់ប្រភពព័ត៌មានដល់អ្នករៀបចំគោលនយោបាយ និងអ្នកធ្វើផែនការពាក់ព័ន្ធនឹងវិស័យជលផល។

## ១.៣ វិធីសាស្រ្តក្នុងការរៀបចំ

គោលការណ៍នេះរៀបចំឡើងដូចខាងក្រោម៖

- ស្រាវជ្រាវឯកសារដែលពាក់ព័ន្ធនឹងកិច្ចការល្បាត
- សិក្ខាសាលាពិគ្រោះយោបល់[2] ប្រមូលបទពិសោធន៍ដែលបានអនុវត្តជាក់ស្តែងកន្លងមកដោយសហគមន៍មូលដ្ឋាន មន្ត្រីជំនាញរបស់រដ្ឋបាលជលផល អ្នកជំនាញរបស់ស្ថាប័នឯកជន និងអង្គការមិនមែនរដ្ឋាភិបាល
- ផ្អែកទៅលើបទពិសោធន៍ជាក់ស្តែងក្នុងការល្បាតស្រះជម្រកត្រី ក្នុងគម្រោងអភិវឌ្ឍន៍វារីវប្បកម្ម និងសហគមន៍ស្រះជម្រកត្រីប្រកបដោយនិរន្តភាព ផ្អែកសហគមន៍ស្រះជម្រកត្រី (គម្រោងសេហ្វ) និងគម្រោងធនធានជលផលតាមវាលស្រែដំណាក់កាលទី២។

# ២. គោលបំណងល្បាត សមាសភាព និងតួនាទីក្រុមល្បាត

## ២.១ គោលបំណងនៃការល្បាត

ជាទូទៅគោលបំណងសំខាន់នៃការល្បាត គឺដើម្បីការពារ ថែរក្សា អភិរក្សពូជត្រី និងវារីសត្វ ដើម្បីបន្តនូវផលិតកម្មត្រី និងសន្តិសុខស្បៀងទាំងពេលបច្ចុប្បន្ន និងអនាគត។

សកម្មភាពល្បាតក្នុងប្រព័ន្ធស្រះជម្រកត្រីមានគោលបំណងដូចខាងក្រោម៖

[2] សិក្ខាសាលានេះបានធ្វើឡើងនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ នៅខេត្តកំពង់ធំមានការចូលរួមពីប្រធានមន្ទីរកសិកម្ម មន្ត្រី រដ្ឋបាលជលផលថ្នាក់ជាតិ និងក្រោមជាតិ អ្នកជំនាញបច្ចេកទេសវារីវប្បកម្មរបស់ស្ថាប័នឯកជន ប្រធានឬតំណាងសហគមន៍ស្រះជម្រកត្រី។

- ទប់ស្កាត់ការនេសាទខុសច្បាប់គ្រប់ប្រភេទនៅក្នុងប្រព័ន្ធស្រះជម្រកត្រី
- បញ្ជ្រាបការផ្សព្វផ្សាយអំពី អត្ថប្រយោជន៍ កិច្ចការពារ និងថែរក្សាត្រីនៅសហគមន៍ស្រះជម្រកត្រី
- បន្តកិច្ចការគ្រប់គ្រងស្រះជម្រកត្រីសហគមន៍ និងអភិរក្សធនធានជលផលធម្មជាតិតាមវាលស្រែប្រកបដោយនិរន្តភាព។

## ២.២ ការចងក្រងសមាសភាពក្រុមល្បាត

ក្នុងរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសហគមន៍ស្រះជម្រកត្រី មានប្រធានក្រុមល្បាតដែលបានបង្កើតឡើងតាមរយៈការបោះឆ្នោត។ ចំណែកសមាជិកក្រុមល្បាតជ្រើសតាំងដោយមេឃុំ និងអាជ្ញាធរដែនដីពាក់ព័ន្ធ មានសមាសភាពដូចខាងក្រោម៖

- គណៈកម្មការសហគមន៍
- អាជ្ញាធរដែនដី (មេភូមិ អនុភូមិ សមាជិកភូមិ)
- ប្រជាការពារ
- ប្រជាពលរដ្ឋ ឬសមាជិកសហគមន៍

សមាសភាពក្រុមល្បាតអាចមាន ពី២ទៅ៧ក្រុម ហើយក្នុង១ក្រុមមានសមាជិក ២ទៅ៥នាក់ យោងទៅលើទំហំ ចំងាយ ទីតាំង ស្រះជម្រកត្រី និងតំបន់ការពារ ។ ក្រុមនេះត្រូវទទួលស្គាល់ជាផ្លូវការ និងអនុញ្ញាតអោយល្បាតដោយមេឃុំ ។

លើសពីនេះ ប្រធាន និងសមាជិកក្រុមល្បាតគួរមានអត្តចរិកល្អ ជាប្រជាពលរដ្ឋគម្រូ មិនអាចជាអ្នកប្រព្រឹត្តបទល្មើស ឬឃុបខិតជាមួយជនផ្សេងទៀតក្នុងការប្រព្រឹត្តបទល្មើសនេសាទទេ។ ក្រុមល្បាតដំណើរការល្អជាកំលាំងសំខាន់ជួយដល់ អាជ្ញាធរដែនដី សង្កាត់ និងរដ្ឋបាលជលផល ក្នុងការរួមចំណែកលើកកម្ពស់ដល់វិស័យជលផល។

## ២.២ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមល្បាត

តួនាទី និងការទទួលខុសត្រូវរបស់ក្រុមល្បាតត្រូវបានពិភាក្សា និងឯកភាពគ្នាក្នុងពេលដំណើរការរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការ និងបានចែងក្នុងលក្ខន្តិករបស់សហគមន៍ស្រះជម្រកត្រី។

តួនាទី និងការទទួលខុសត្រូវរបស់ក្រុមល្បាតរួមមាន៖

- ទប់ស្កាត់ការដាក់ឧបករណ៍នេសាទនៅក្នុងស្រះជម្រកត្រី នៅតាមផ្លូវត្រីចេញចូលដែលភ្ជាប់ ពីស្រះជម្រកត្រីទៅវាលស្រែ
- រឹបអូសឧបករណ៍ដែលរកឃើញនៅផ្លូវត្រីចេញចូល នៅក្នុងស្រះជម្រកត្រី នៅតំបន់ការពារ

- រាយការណ៍ករណីបទល្មើសជាបន្ទាន់ ថតរូប និងប្រមូលវត្ថុតាង ប្រគល់ទៅអាជ្ញាធរដែនដី កងកំលាំងមានសមត្ថកិច្ច និងមន្ត្រីជលផល ដែលនៅជិតជាងគេបំផុត ដើម្បីចាត់វិធានការទៅតាមច្បាប់។

# ៣. ទីតាំង និងពេលវេលា ល្បាត

សកម្មភាពល្បាត អនុលោមទៅតាមលក្ខន្តិក រួមទាំងបទបញ្ញត្តិសហគមន៍ ស្តីអំពីប្រភេទឧបករណ៍នេសាទ ដែនអភិរក្ស និងតំបន់ការពារ ដែលខុសៗគ្នាទៅតាមសហគមន៍នីមួយៗ ។

សកម្មភាពល្បាតអាចអនុវត្តជារួម ផ្តោតលើទីតាំង ឬផ្នែកនីមួយៗនៃប្រព័ន្ធស្រះជម្រកត្រីតាមរដូវ កាល និងពេលវេលាដូចខាងក្រោម៖

**៣.១ ផ្នែកស្រះជម្រកត្រី៖** នៅរដូវប្រាំងស្រះជម្រកត្រីជាកន្លែងដែលត្រីអាចរស់នៅបាន ហេតុនេះវាបានទាក់ទាញអ្នកនេសាទមកនេសាទនៅទីនេះ ទោះបីជាពួកគាត់ដឹង ឬអ្នកខ្លះមិនដឹងថាកន្លែងនេះជាតំបន់អភិរក្សត្រូវបានហាមឃាត់ដោយច្បាប់។

**ក្នុងករណីស្រះនៅក្នុងភូមិ** ប្រសិនបើប្រជាពលរដ្ឋបានយល់ដឹងអំពីអត្ថប្រយោជន៍ស្រះជម្រកត្រី ច្បាប់ជលផល និងលក្ខន្តិកសហគមន៍ស្រះជម្រកត្រី ការល្បាតស្ទើរតែមិនចាំបាច់ ។

**ក្នុងលក្ខខណ្ឌដែលទីតាំងស្រះនៅឆ្ងាយពីភូមិឬនៅជិតភូមិ** ការល្បាតត្រូវធ្វើអោយបានជាប្រចាំឬញឹកញាប់ ជាពិសេសដើមរដូវប្រាំង (ខែវិច្ឆិកាឬធ្នូ) ដល់ដើមរដូវវស្សា (ខែមេសាឬឧសភា)។

**៣.២ ផ្នែកផ្លូវត្រីចរាចរ៖** ផ្លូវត្រីចរាចរ រួមមានប្រឡាយ អូរ ព្រែក និងទម្រង់ផ្លូវទឹកផ្សេងៗទៀតដែលភ្ជាប់ស្រះជម្រកត្រីទៅនឹងប្រព័ន្ធអេកូឡូស៊ីវាលស្រែតាមរយៈផ្លូវត្រីចេញចូល។ ផ្លូវត្រីចរាចរនេះដើរ តួនាទីយ៉ាងសកម្មក្នុងការអនុញ្ញាតអោយត្រីបំលាស់ទីពីស្រះជម្រកត្រីទៅវាលស្រែ ដើម្បីពងកូននៅរដូវវស្សា និងត្រឡប់មកស្រះជម្រកត្រីវិញដើម្បីជ្រកកោននៅរដូវប្រាំង។ ជាញឹកញាប់សកម្មភាពនេសាទខុសច្បាប់ត្រូវបានគេរកឃើញនៅតាមផ្លូវត្រីចរាចរ ជាពិសេសនៅតំបន់ជិតស្រះជម្រកត្រី។ ការល្បាតនៅផ្នែកនេះសំខាន់ណាស់ដើម្បីត្រួតពិនិត្យការរាំងខ្ទប់ចរាចរត្រី ជាពិសេស នៅដើមរដូវវស្សាចាប់ពីខែឧសភាដល់កក្កដា និងចុងរដូវវស្សាចាប់ពីខែវិច្ឆិកាដល់ធ្នូ។ ការល្បាតអំឡុងពេលនេះបានទៀងទាត់ជួយសម្រួលដល់ត្រីអោយទៅពងកូន និងត្រឡប់ចូលស្រះវិញដោយសុវត្ថិភាព។

**៣.៣ ផ្នែកវាលស្រែលិចទឹក៖** ជាកន្លែងដែលត្រី បង្កកំណើត ផ្តល់ចំណីធម្មជាតិសម្បូណ៌បែប ពងកូន និងធំធាត់។ ផ្នែកនេះជាទីកន្លែងដែលប្រជាពលរដ្ឋទូទៅនេសាទត្រី សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។ សហគមន៍ភាគច្រើនបានកំណត់ទុកតំបន់ការពារក្នុងទំហំផ្សេងៗគ្នា និងចែងក្នុងលក្ខន្តិក។ ក្រៅពីតំបន់ការពារ សកម្មភាពល្បាតអាចអនុវត្តនៅវាលស្រែ ដែលមិនកំណត់រយៈចំងាយ តែអាចផ្តោតលើសិទ្ធដែលប្រជា

ពលរដ្ឋមាន គឺអាចរាយការណ៍នៅពេលឃើញមានបទល្មើសទាក់ទងនឹងការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និងសកម្មភាពខុសច្បាប់ ដូចជា កាប់ប្រឡាយបង្ហូរទឹកយកត្រី ដាក់ឧបករណ៍នេសាទត្រីខុសច្បាប់(ការឆក់ដោយប្រើគ្រឿងអេឡិចត្រូនិច)។

ដោយសារតែផ្នែកនេះមានផ្ទៃធំល្វឹងល្វើយ ធៀបចំនួនក្រុមល្បាតដែលមានកំណត់ វាពិបាកក្នុងការល្បាត និងគ្រប់គ្រង។ ក្នុងករណីសហគមន៍មានបំណងល្បាតនៅតាមវាលស្រែ ក្រៅពីតំបន់ការពារ គេគួរតែពិភាក្សា និងឯកភាពរវាងមន្ត្រីជំនាញជលផល មេឃុំឬក្រុមប្រឹក្សាឃុំ ជាពិសេសកំណត់ ចំងាយ ពេលវេលា ភាពញឹកញាប់ក្នុងការល្បាត និងផ្តោតលើការប្រើប្រាស់ឧបករណ៍នេសាទ។

**ចំណុចបន្ថែមទី១៖** ទំនាក់ទំនងរវាងភាពញឹកញាប់នៃល្បាត សកម្មភាពដែលបានអន្តរាគមន៍ និងទីតាំងស្រះជម្រកត្រី

- សកម្មភាពអន្តរាគមន៍ ដូចជាការជីកស្តារជម្រៅស្រះ ការដាក់សម្រាស់ក្នុងស្រះជម្រកត្រី ជួយកាត់បន្ថយសកម្មភាពល្បាត។
- ទីតាំងរបស់ស្រះជម្រកត្រី ផ្លូវត្រីចេញចូល តំបន់ការពារ ស្ថិតនៅក្នុងភូមិ ឬក្បែរភូមិ ក៏ជួយរួមចំណែកក្នុងការកាត់បន្ថយសកម្មភាពល្បាតផងដែរ។
- ស្រះជម្រកត្រីរីងរាក់ និងទីតាំងផ្នែកទាំងបីនេះនៅឆ្ងាយពីភូមិ កិច្ចការល្បាតគួរតែញឹក ញាប់។

**ចំណុចបន្ថែមទី២៖** ក្រុមល្បាតត្រូវសិក្សាស្វែងយល់អំពី ទំលាប់ និងសកម្មភាពនេសាទខុសច្បាប់របស់ជនល្មើស ដូចជាម៉ោងពេល និងទីកន្លែងដែលជនល្មើសទៅនេសាទខុសច្បាប់ជាញឹកញាប់។

**ចំណុចបន្ថែមទី៣៖** ឧទាហរណ៍ អំពីការអនុវត្តជាក់ស្តែងរបស់ក្រុមល្បាតនៅសហគមន៍ស្រះជម្រកត្រីក្អែកងូត នៅភូមិកំពង់ឈើទាល ឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។

- នៅរដូវប្រាំង ចន្លោះខែវិច្ឆិកា ដល់ខែឧសភា៖ ក្រុមល្បាតប្រើប្រាស់ម៉ូតូ ដើម្បីល្បាតក្នុង រយៈពេលប្រមាណ៦ម៉ោង(មិនជាប់គ្នា) ក្នុងមួយថ្ងៃ។
  - នៅពេលព្រឹកចាប់ពីម៉ោង៥ដល់ម៉ោង៧ ពេលរសៀលចាប់ពីម៉ោង១ដល់ម៉ោង៣។
  - នៅវេលារសៀល ចាប់ពីម៉ោង ៥ ដល់ម៉ោង ៧យប់។
- ក្រៅពីពេលវេលាល្បាតជាទៀងទាត់ដែលបានកំណត់ជាមួយសមាជិកផ្សេងទៀត ក្រុមល្បាតបានចុះត្រួតពិនិត្យក្រៅពីម៉ោងដែលបានកំណត់។
- នៅរដូវវស្សា ចាប់ពីខែមិថុនា ដល់ខែតុលា ក្រុមល្បាតប្រើប្រាស់ទូកដើម្បីល្បាតទាំងពេលថ្ងៃ និងពេលយប់។

**ចំណុចបន្ថែមទី៤៖ ទំនាក់ទំនងរវាងធាតុអាកាស និងការនេសាទខុសច្បាប់**

ធាតុអាកាសក៏មានទំនាក់ទំនងជាមួយការនេសាទខុសច្បាប់ ហេតុនេះក្រុមល្បាតគួរតែបន្ថែមចំនួនសកម្មភាពល្បាតទៅតាមពេលវេលាដូចខាងក្រោម៖

- នៅដើមរដូវវស្សា(ចាប់ពីខែឧសភាដល់កក្កដា) នៅពេលមានភ្លៀងធ្លាក់ច្រើន ជនល្មើសនេសាទខុសច្បាប់ក៏ចាប់ផ្តើមប្រតិបត្តិការ។
- ចុងរដូវវស្សា(ចាប់ពីខែវិច្ឆិកាដល់ធ្នូ) ជារដូវកាលត្រជាក់ខ្យល់ធ្លាក់ពីជើង ត្រីវិលត្រលប់មកពីវាលស្រែចូលស្រះជម្រកត្រីវិញ អ្នកនេសាទខ្លះស្ទាក់ចាប់ត្រីដោយប្រើឧបករណ៍ខុសច្បាប់ (ឆក់ ស្បៃមុង ដាក់ព្រួលរាំងស្ទះចរាចរណ៍ត្រី)។

# ៤. ជំហានក្នុងការល្បាតស្រះជម្រកត្រី

## ជំហានទី១៖ ការយល់ដឹងពីច្បាប់ជលផល និងលក្ខន្តិកៈរបស់សហគមន៍

សមាជិកក្រុមល្បាតទាំងអស់ត្រូវតែទទួលការបណ្តុះបណ្តាលលើប្រធានបទជាច្រើនដើម្បីអនុវត្តសកម្មភាពល្បាតបានត្រឹមត្រូវ ជោគជ័យ ប្រកបដោយសុវត្ថិភាព។

**ប្រធានបទបណ្តុះបណ្តាលរួមមាន៖**

- ច្បាប់ជលផលមាត្រាពាក់ព័ន្ធកិច្ចការពារ និងអភិរក្ស ឧបករណ៍នេសាទ ទោសទណ្ឌ
- លក្ខន្តិកៈរបស់សហគមន៍ស្រះជម្រកត្រី (ទីកន្លែងអភិរក្ស ដែនការពារ ឧបករណ៍នេសាទ និងដំណោះស្រាយ)
- តួនាទី និងការទទួលខុសត្រូវក្នុងសកម្មភាពល្បាត
- ប្រព័ន្ធស្រះជម្រកត្រីសហគមន៍ និងមុខងាររបស់វា
- របៀបប្រើប្រាស់ឧបករណ៍ល្បាតដូចជា វិទ្យុទាក់ទង កាមេរ៉ាល្បាត ជាដើម
- យន្តការដោះស្រាយបទល្មើស
- ការរៀបចំផែនការសកម្មភាពល្បាត អោយបានច្បាស់លាស់
- ការរៀបចំឯកសារកត់ត្រាដើម្បីត្រួតពិនិត្យ និងតាមដាន (សកម្មភាពល្បាត សកម្មភាពជនល្មើស ឧបករណ៍ខុសច្បាប់ នៅក្នុងពេលល្បាត និងរាយការណ៍)។
- ការវាយតម្លៃអំពីស្ថានភាពមុនពេលល្បាត៖ មុនពេលចាប់ផ្តើមសកម្មភាព ក្រុមល្បាតវាយតម្លៃអំពីស្ថានភាព បទល្មើសនៃផ្នែកទាំងបីនៃប្រព័ន្ធស្រះជម្រកត្រី ទីតាំង និងពេលវេលាដែលសកម្មភាពនេសាទខុសច្បាប់កើតឡើងជាញឹកញាប់ ប្រភេទឧបករណ៍ខុសច្បាប់ដែលរកឃើញដោយសហគមន៍ ប្រៀបធៀបសកម្មភាពខុសច្បាប់ សិក្សាស្វែងរកមូលហេតុ និងដំណោះស្រាយចំនួនករណីដែលត្រូវបានរាយការណ៍ និងដំណោះស្រាយដោយអាជ្ញាធរ ដែនដី។

## ជំហានទី២៖ សម្ភារៈល្បាត

ដើម្បីល្បាតជោគជ័យ ក្រុមល្បាតគួរត្រៀមសម្ភារៈ និងឯកសារមួយចំនួនដូចខាងក្រោម៖
វិទ្យុទាក់ទង ទូរស័ព្ទ លេខទូរស័ព្ទរបស់អាជ្ញាធរពាក់ព័ន្ធ អាវភ្លៀង (នៅរដូវវស្សា) ពិល ទូក ឬ ការណូត មុង អង្រឹង ឯកសណ្ឋានល្បាត ស្បែកជើងកវែង កាមេរ៉ាដើរដោយពន្លឺព្រះអាទិត្យ ពេងយាម សម្ភារៈសង្គ្រោះបន្ទាន់។ ម៉្យាងទៀត ក្រុមល្បាតក៏ត្រូវចេះប្រើប្រាស់ឧបករណ៍ល្បាតទាំងនេះ ដូចជាការតភ្ជាប់វិទ្យុទាក់ទងជាមួយអាជ្ញាធរដែនដី (ឃុំ ប៉ូលីស) ការតភ្ជាប់ និងប្រើប្រាស់កាមេរ៉ាដើរដោយពន្លឺព្រះអាទិត្យ ។ ក្នុងករណីដែលសហគមន៍មានលទ្ធភាពបំពាក់កាមេរ៉ាដើរដោយពន្លឺព្រះអាទិត្យ គួរតែប្រើប្រាស់ឧបករណ៍នេះ ព្រោះវាជួយយ៉ាងខ្លាំងដល់ការល្បាត ដូចជាសន្សំពេលវេលាដល់ក្រុមល្បាត អាចរកឃើញជនល្មើសដោយមានភស្តុតាង។

## ជំហានទី៣៖ វិធានការអំឡុងពេលល្បាត

នៅពេលដែលក្រុមល្បាតឃើញឬជួបប្រទះប្រភេទបទល្មើសណាមួយ ដូចជា ឧបករណ៍ខុសច្បាប់ សកម្មភាពនេសាទខុសច្បាប់ កើតឡើងនៅតាមប្រព័ន្ធស្រះជម្រកត្រី៖

- ក្រុមល្បាតអាចថតរូប ជនប្រព្រឹត្តបទល្មើស ព្រមទាំងវត្ថុតាង រាយការណ៍ បញ្ជូនមកអាជ្ញាធរដែនដី និងជំនាញ ដែលនៅជិតបំផុតដើម្បីដោះស្រាយ។
- ក្រុមល្បាតណែនាំ និងអប់រំជនល្មើស ដោយមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ
- ករណីដែលជនល្មើសនោះនៅតែបន្តសកម្មភាពផ្ទុយពីលក្ខន្តិកនិងបទប្បញ្ញត្តិរបស់សហគមន៍ ក្រុមល្បាតរាយការណ៍ជាបន្ទាន់ជូនទៅអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញជលផលដើម្បីដោះស្រាយតាមច្បាប់។
- ការផាកពិន័យ ឬ ការដាក់ទណ្ឌកម្មចំពោះជនល្មើសត្រូវអនុលោមតាមច្បាប់ស្តីពីជលផល និងតារាងសងការខូចខាតលើបទល្មើសជលផលផ្សេងៗ។ ក្នុងទោសប្បញ្ញត្តិ និងកម្រិតការផាកពិន័យចំពោះសកម្មភាពនេសាទខុសច្បាប់ មានចែងក្នុងលក្ខន្តិករបស់សហគមន៍នីមួយៗ និងមានកម្រិតខុសៗគ្នាទៅតាមសហគមន៍។
- រាល់សំណងខូចខាតទាំងអស់ត្រូវមានវិក័យប័ត្រ និងកំណត់ហេតុត្រឹមត្រូវដែលមានការទទួលដឹងពីអាជ្ញាធរភូមិ ឃុំ និងប៉ុស្តិ៍រដ្ឋបាល ឬ ជំនាញជលផល ។

សូមមើលបន្ថែមលើ តារាងឧបសម្ព័ន្ធ១៖ វិធានការជំនួយដល់ក្រុមល្បាតដើម្បីដោះស្រាយ បានបរិយាយប្រភេទបទល្មើស ប្រភេទឧបករណ៍និងដំណោះស្រាយ។

## ជំហានទី៤៖ ការត្រួតពិនិត្យ និងវាយតម្លៃ

ប្រធានសហគមន៍ឬមេឃុំពិនិត្យជាប្រចាំអំពីសកម្មភាពល្បាតដើម្បីវាយតម្លៃពីប្រសិទ្ធភាពសកម្មភាពល្បាត។ ដំណើរការពិនិត្យរួមមាន៖

- ពិនិត្យមើលសៀវភៅកំណត់ហេតុកត់ត្រាល្បាត
- ពិនិត្យមើលរបាយការណ៍ល្បាត
- ចូលរួមត្រួតពិនិត្យសកម្មភាពល្បាត
- ចូលរួមវិនិច្ឆ័យករណីនេសាទនៅពេលក្រុមល្បាតរាយការណ៍
- រាយការណ៍ភ្លាមៗទៅអាជ្ញាធរដែលពាក់ព័ន្ធដូចជា ឃុំ ខណ្ឌរដ្ឋបាលជលផល ប៉ូលីស។

ជារៀងរាល់ខែគណៈកម្មការគ្រប់គ្រងស្រះជម្រកត្រីរាយការណ៍នូវលទ្ធផលនៃការល្បាតព្រមទាំងពិភាក្សារកដំណោះស្រាយបញ្ហាដែលជួបប្រទះពេលល្បាត ជូនកិច្ចប្រជុំប្រចាំខែរបស់ខ្លួន និងជាមួយឃុំ។

ទន្ទឹមនឹងការអនុវត្តច្បាប់ ក្រុមល្បាត និងប្រធានសហគមន៍ គួរតាមដានអំពីនិន្នាការនៃសកម្មភាពបទល្មើស (កើន ឬ ថយ)។ ប្រសិនបើបទល្មើសកើន ប្រធានសហគមន៍ និងអាជ្ញាធរដែនដីគួរពិភាក្សារកមូលហេតុអំពីកំណើនបទល្មើស និងរៀបចំផែនការសកម្មភាព (ឧទាហរណ៍ ការផ្សព្វផ្សាយអត្ថប្រយោជន៍ស្រះជម្រកត្រីសហគមន៍ លក្ខន្តិករបស់សហគមន៍ ការអនុវត្តច្បាប់ជលផល ។ល។) ដើម្បីកាត់បន្ថយបទល្មើសទាំងនេះ។

ការត្រួតពិនិត្យ វាយតម្លៃនិងរៀបចំផែនការសកម្មភាពគួរធ្វើជាប្រចាំ។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖ វិធានការជំនួយដល់ក្រុមល្បាតដើម្បីដោះស្រាយ

| | | ដំណោះស្រាយ(ករណីជួបជនល្មើស) | ដំណោះស្រាយ (ករណីមិនជួបជនល្មើស) |
|---|---|---|---|
| ប្រភេទបទល្មើស ក្នុងកន្លែងអភិរក្សសហគមន៍(ស្រះជម្រកត្រី និង តំបន់ការពារ) | សកម្មភាពនេសាទដែលខុសទៅនឹងច្បាប់ស្ដីពីជលផល | អនុវត្តតាមច្បាប់ស្ដីពីជលផល | |
| | ការឃុបឃិតបទល្មើសផ្សេងៗ | អនុវត្តតាមច្បាប់ស្ដីពីជលផល | |
| | ការនេសាទដោយប្រើឧបករណ៍នេសាទស្របច្បាប់ស្ដីពីជលផលនៅក្នុងកន្លែងអភិរក្សនិងតំបន់ការពារ | សងការខូចខាតក្នុងចំនួនទឹកប្រាក់(កំណត់នៅក្នុងលក្ខន្តិកៈរបស់សហគមន៍រៀងៗខ្លួន) វត្ថុតាងមិនប្រគល់អោយវិញនោះទេ | យកឧបករណ៍ចេញ |
| | ការចាក់ចូល និងចាក់គរសំរាមនៅក្នុង ឬក្បែរស្រះជម្រកត្រី | សងការខូចខាត ក្នុងចំនួនទឹកប្រាក់(កំណត់នៅក្នុងលក្ខន្តិកៈរបស់សហគមន៍រៀងៗខ្លួន) | យកសំរាមចេញ |
| ប្រភេទឧបករណ៍ខុសច្បាប់ | ឧបករណ៍ឆក់ | អនុវត្តតាមច្បាប់ស្ដីពីជលផល | |
| | លូស្បៃមុង | អនុវត្តតាមច្បាប់ស្ដីពីជលផល | |
| | | | |

| | | | |
|---|---|---|---|
| | ស្បៃមុង ឬសាច់ដៃ | អប់រំណែនាំជនល្មើស អំពីលក្ខន្តិកសហគមន៍ស្រះជម្រកត្រី និងច្បាប់ជលផល(ចំពោះមាត្រាដែលពាក់ព័ន្ធ) កុំអោយប្រព្រឹត្តជាលើកទី២ | យកឧបករណ៍ចេញ |
| | | | |
| | ប្រឹស១០០ (ឧបករណ៍ទំនើប) | អនុវត្តតាមច្បាប់ស្តីពីជលផល | យកឧបករណ៍ប្រគល់ជូនសមត្ថកិច្ច |
| | លបឬស្បៃមុង កាត់ផ្លូវត្រីចេញចូល | អនុវត្តតាមច្បាប់ស្តីពីជលផល | យកឧបករណ៍ចេញ |

## ឧបសម្ព័ន្ធ ២: ទម្រង់កត់ត្រាពីសកម្មភាពចុះល្បាត (អនុវត្តនៅគម្រោងសេហ្វ)

| ថ្ងៃចុះល្បាត | ចំនួនអ្នកចូលរួម | ស្រី | ចំនួនករណីការនេសាទខុសច្បាប់ | ចំនួនអ្នកប្រព្រឹត្ត | ទីតាំងប្រព្រឹត្ត | ម៉ោងឃើញ | សកម្មភាពបន្ទាប់ | កត់សំគាល់ប្រភេទករណីការ) (នេសាទខុសច្បាប់ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

## ឧបសម្ព័ន្ធ ៣៖ គម្រូសេចក្តីសម្រេចការទទួលស្គាល់ក្រុមល្បាត នៅសហគមន៍ស្រះជម្រកត្រី

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣ ✪ ៩៩

**ខេត្ត** **កំពង់ធំ**

**ស្រុក** **កំពង់ស្វាយ**

**សាលាឃុំ** **សាន់គ**

លេខ:...3.985/2021

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើត និងទទួលស្គាល់ក្រុមល្បាតការពារ និងគ្រប់គ្រងសហគមន៍ស្រះជម្រកត្រី**

**ត្រពាំងអង្កាញ់វៀន**

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់។
- យោងអនុក្រឹត្យ លេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និង ភារកិច្ចទៅឱ្យក្រុមប្រឹក្សា ឃុំ-សង្កាត់។
- យោងសេចក្តីសំរេចលេខ ០៧០ សសរ.គយស ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់គណៈកម្មាធិការជាតិ គាំទ្រឃុំ-សង្កាត់។

**សម្រេច**

**ប្រការ១** ៖បង្កើតនិងទទួលស្គាល់ក្រុមល្បាតការពារសហគមន៍ស្រះជម្រកត្រី **ត្រពាំងអង្កាញ់វៀន** នៅក្នុងភូមិក្រសាំង ក ឃុំសាន់គ ស្រុកកំពង់ស្វាយ ដែលមានសមាសភាពចំនួន ០៣ក្រុមដូចខាងក្រោម៖

**ក្រុមទី១** (**ល្បាតពីថ្ងៃចន្ទ ដល់ ថ្ងៃអង្គារ**)

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | លោក សុខ អុល | ប្រធាន |
| ២ | លោក ជួប ម៉ុន | អនុប្រធាន |
| ៣ | លោក ព្រំ សារិទ្ធ | សមាជិក |
| ៤ | លោក ទុយ យាង | សមាជិក |

**ក្រុមទី២** (**ល្បាតពីថ្ងៃពុធដល់ ថ្ងៃព្រហស្បតិ៍**)

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | លោក វៀន រុំ | ប្រធាន |
| ២ | លោក ថាំង ប៉ុញ | អនុប្រធាន |
| ៣ | លោក មុំ គ្រុយ | សមាជិក |
| ៤ | លោក ទូត សំណាង | សមាជិក |